01345333

Declassified to Public
27 June 2019

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 11 / 2016
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើ E448 របស់មេធាវីការពារក្តី នួន ជា សុំឲ្យទទួលយកឯកសារនានាធ្វើជាឯកសារភ័ស្តុតាង និង កោះហៅសាក្សីបន្ថែមពីររូប (សម្ងាត់)

TRIAL CHAMBER * E.C.C.C. * CHAMBRE DE PREMIÈRE INSTANCE

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានសំណើមួយ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់ជាឯកសារសម្ងាត់នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ ដោយមេធាវីការពារក្តី នួន ជា សុំឱ្យទទួលយកជាឯកសារភ័ស្តុតាងនូវអត្ថបទសារព័ត៌មានចំនួនពីរ មុនការផ្តល់សក្ខីកម្មរបស់សាក្សី ឡុង សាត (2-TCW-1065) (ឯកសារ E448.2 និង E448.3) ("អត្ថបទ") និង សុំឱ្យកោះហៅសាក្សីបន្ថែមចំនួនពីររូបឱ្យមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបះបោរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងពាក់ព័ន្ធនឹងសាក្សី 2-TCW-1065 ដែលនឹងផ្តល់សក្ខីកម្មចំពោះអង្គហេតុលក្ខណៈនៃជម្លោះប្រដាប់អាវុធ (ឯកសារ E448)។ អត្ថបទទាំងនេះ រៀបរាប់អំពីប្រវត្តិរបស់សាក្សីបន្ថែមពីររូប ដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះបានស្តាប់សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ឆ្លើយតបទៅនឹងសំណើនេះ នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦។ ភាគីផ្សេងទៀត មិនបានជំទាស់ទៅនឹងការទទួលយកអត្ថបទទាំងនេះជា

ឯកសារភ័ស្តុតាងនោះឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ទោះបីជាសាក្សីដែលបានស្នើមានភាពជាប់ពាក់ព័ន្ធ តែវាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ក្នុងការសម្រេចថាតើពួកគាត់គួរតែត្រូវបានកោះហៅដែរ ឬយ៉ាងណា ដោយសារនាពេលនេះ ជាដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះហើយ។ មេធាវីការពារក្តី ខៀវ សំផន ពុំជំទាស់ទៅនឹងសំណើសុំនេះឡើយ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ៧៧-៨០ សេចក្តីព្រាង)។ នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា បានដាក់សំណើសុំផ្ទាល់មាត់ឱ្យទទួលយកប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សីពីរនាក់ដែលបានស្នើសុំ ដែលប្រតិចារឹកនៃកិច្ចសម្ភាសទាំងនោះមានតែជាភាសាខ្មែរប៉ុណ្ណោះ ("ប្រតិចារឹក")។ ភាគីផ្សេងទៀតពុំបានជំទាស់ទៅនឹងសំណើសុំឱ្យទទួលយកប្រតិចារឹកនេះធ្វើជាឯកសារភ័ស្តុតាងនោះឡើយ (ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែ តុលា ទំព័រ ៤៥-៤៧ សេចក្តីព្រាង)។

២. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់មួយដោយទទួលយកអត្ថបទ និង ប្រតិចារឹកទាំងនេះធ្វើជាឯកសារភ័ស្តុតាង និង បានពន្យារការសម្រេចលើបញ្ហាថាតើគួរកោះហៅបុគ្គលទាំងពីររូបនេះធ្វើជាសាក្សីបន្ថែមទៀត ឬយ៉ាងណា (ប្រតិចារឹកសវនាការ ថ្ងៃទី ២៧ ខែ តុលា ទំព័រ ៤៨ សេចក្តីព្រាង)។

៣. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះអាចទទួលយកនូវភ័ស្តុតាងទាំងឡាយណា ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងនោះក៏បំពេញផងដែរនូវបទដ្ឋាន*ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មី ស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏តម្រូវផងដែរថា ភាគីដែលស្នើសុំឱ្យទទួលយកភ័ស្តុតាងថ្មីត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលខ្លួនបានស្នើសុំដាក់នោះ មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចត្រូវបានរកឃើញ ទោះបីជាបានយកចិត្តទុកដាក់សម-

ស្របហើយក៏ដោយ។ ទោះបីជាយ៉ាងណា នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូង បានទទួលយកភ័ស្តុតាងនានាដែលពុំបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមទាំងក្នុងករណីដែលភ័ស្តុតាងពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង និង ក្នុងករណីដែលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា និង ករណីដែលឯកសារដែលបានស្នើសុំនេះ គឺជាភ័ស្តុតាងដោះបន្ទុកដែលតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ (*សូមមើល* ឯកសារ E319/36/2)។

៤. អត្ថបទទាំងនេះបានបោះពុម្ពផ្សាយនៅក្នុងខែ កក្កដា និង សីហា ឆ្នាំ ២០១៥ នៅក្នុងទស្សនាវដ្តី "ស្វែងរកការពិត"របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ប្រតិចារឹកកត់ត្រាកិច្ចសម្ភាសន៍ជាមួយសាក្សីបន្ថែមពីររូបដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្ម ដែលបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ មេធាវីការពារក្តី នួន ជា បានលើកឡើងថា មេធាវីការពារក្តីបានដឹងពីវត្តមាននៃអត្ថបទ និង ប្រតិចារឹកទាំងនេះ នៅក្រោយខែ កញ្ញា ឆ្នាំ ២០១៦ នៅពេលដែលសេចក្តីរាយការណ៍ព័ត៌មានផ្ទៃក្នុងរបស់ អ.វ.ត.ក យោងលើអត្ថបទកាសែតកម្ពុជាមួយ ដែលបានរៀបរាប់ពីប្រវត្តិរបស់បុគ្គលទាំងនេះ។ ទោះបីជាយ៉ាងណា ជាក់ស្តែង ឯកសារទាំងនេះអាចរកបានជាសាធារណៈ ជាងរយៈពេលមួយឆ្នាំមកហើយ។ ដូចនេះ សំណើនេះគួរតែត្រូវបានដាក់ឆាប់ជាងនេះប្រកបដោយការយកចិត្តទុកដាក់ត្រឹមត្រូវ ហេតុដូច្នេះ ការដាក់សំណើនេះនៅពេលនេះត្រូវបានចាត់ទុកថាមានភាពយឺតយ៉ាវ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះពិចារណា ថាតើជាប្រយោជន៍នៃយុត្តិធម៌ដែរ ឬទេ ក្នុងការទទួលយកឯកសារទាំងនេះធ្វើជាឯកសារភ័ស្តុតាង។

៥. អង្គជំនុំជម្រះយល់ឃើញថា អត្ថបទ និង ប្រតិចារឹកទាំងនេះ បំពេញទៅតាម*បទដ្ឋាននៃការបញ្ជាក់បឋម* ពីភាពពាក់ព័ន្ធ ភាពជឿជាក់បាន និង យថាភាព ដែលតម្រូវសម្រាប់ការទទួលយកឯកសារតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ឯកសារទាំងនេះអាចមានភាពពាក់ព័ន្ធ ហើយមេធាវីការពារក្តី នួន ជា អាចយកមកប្រើប្រាស់ដើម្បីតាំងសំណួរ និង ពិនិត្យភ័ស្តុតាងរបស់សាក្សី ឡុង សាត (2-TCW-1065)។ នេះបង្ហាញឱ្យឃើញនូវប្រយោជន៍នៃយុត្តិធម៌ដែលតម្រូវឱ្យទទួលយកឯកសារទាំងនេះ។

៦. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងទទួលយកអត្ថបទ និង ប្រតិចារឹកទាំងនេះធ្វើជាឯកសារភស្តុតាង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូង ដាក់លេខយោងជាឯកសារ E3/10714 និង E3/10715 សម្រាប់អត្ថបទទាំងនេះ និង ដាក់លេខយោងជាឯកសារ E3/10716 និង E3/10717 សម្រាប់ប្រតិចារឹកទាំងនេះ។ អង្គជំនុំជម្រះពន្យារពេលចេញសេចក្តីសម្រេចលើបញ្ហាថាតើត្រូវកោះហៅសាក្សីបន្ថែមពីររូប ដែលបានលើកឡើងនៅក្នុងសំណើនេះ ឬ យ៉ាងណា ដោយសារតែអង្គជំនុំជម្រះចាំបាច់ស្តាប់សក្ខីកម្មរបស់សាក្សីឡុង សាត (2-TCW-1065) ជាមុនសិន ដើម្បីវាយតម្លៃឱ្យបានពេញលេញទៅលើលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ហើយថាតើវាជាប្រយោជន៍នៃយុត្តិធម៌ដែរ ឬ យ៉ាងណា។

៧. អនុស្សរណៈនេះ ជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំ E448។